# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ

website ៖ www.hoksavann.org

ថ្ងៃទី១ មិថុនា ២០០៩



រៀងរាល់ឆ្នាំនៅថ្ងៃទី១២មិថុនា ជាទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ។ ច្បាប់ប្រឆាំងនឹងពលកម្មកុមារនេះមាន១៦មាត្រា ដែលហាមប្រាមកុមារមានអាយុក្រោម១៨ឆ្នាំ ធ្វើការក្នុងចំការមីន ធ្វើទាហាន ធ្វើការស៊ីឈ្នួលបំរើគេក្នុងទីផ្សេងៗ មានបំរើគេតាមផ្ទះជាដើម ។ ច្បាប់បានហាមជាដាច់ខាតចំពោះការលក់ដូរកុមារ មានលក់ឲ្យបំរើផ្លូវភេទជាដើម ។ សូម្បីឪពុកម្តាយយកកូនរបស់ខ្លួន ដែលមានអាយុក្រោម១៨ឆ្នាំ ឲ្យទៅស៊ីឈ្នួលគេ ក៏ខុសច្បាប់ ។ ការបង្ខំកុមារឲ្យធ្វើជាស្រីពេស្យាចារ ត្រូវមានទោសយ៉ាងធ្ងន់ ។ សូម្បីថតរូបកុមារអាសអាភាស ក៏ច្បាប់ហាមប្រាមជាដាច់ខាត ។ ការបង្ខំកុមារឲ្យរត់អាភៀន ឲ្យធ្វើកិច្ចការក្នុងកន្លែងមានជាតិពុល ឬធ្វើការធ្ងន់ និងឲ្យធ្វើការក្នុងទីកន្លែងមានគ្រោះថ្នាក់ ជាការខុសច្បាប់ ។ ក្នុងវ័យកុមារភាព គ្រួសារមានឪពុកម្តាយជាដើម ត្រូវបញ្ជូនពួកគេទៅសាលារៀន ដែលមានការឧបត្ថម្ភពីរដ្ឋ ។ ច្បាប់ប្រឆាំងនឹងពលកម្មកុមារនេះ បានចុះហត្ថលេខាយល់ព្រមដោយប្រទេសចំនួន១៦៩ក្នុងពិភពលោក ដែលនៅក្នុងចំណោមនោះ ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេ-ខាយល់ព្រម នៅថ្ងៃទី១៨ មីនា ២០០៦ ។

ចំពោះកុមារខ្មែរស្ទើរតែគ្រប់សម័យ មិនត្រូវបានរង្គគោរពឡើយ ។ សម័យអាណានិគមនិយមបារាំង កុមារខ្មែរស្ទើរតែទាំងអស់បានត្រូវគ្រូបង្រៀន និងម្តាយឪពុកវាយដំដូចសត្វធាតុ (របៀបអប់រំសម័យបូរាណ) ។ សូម្បីអាណានិ-

គមនិយមបារាំងបានចាកចេញពីប្រទេសកម្ពុជា ខ្មែរបានឯករាជ្យហើយក៏ដោយ ក៏គ្រូបង្រៀនខ្មែរនៅតែបន្តវាយដំកូនសិស្សតមកទៀតដែរ ។ សូម្បីព្រះសង្ឃព្រះពុទ្ធសាសនាដែលធ្វើគ្រូបង្រៀន ដែលជាអ្នកកាន់ធម៌វិន័យ ក៏វាយដំកូនសិស្សដែរ ។ ការវាយដំកូនសិស្សរបៀបនេះ នាំឲ្យកុមារខ្មែរមានការភ័យបាក់ស្បាត នាំឲ្យទន់ខ្សោយខាងបញ្ញាស្មារតី នាំឲ្យពួកគេមានការចងគំនុំពេលពួកគេធំឡើង ។ ការបង្រៀនដោយការវាយដំនេះ មិនត្រឹមតែខុសនឹងសិទ្ធិកុមារប៉ុណ្ណោះទេ គឺខុសនឹងក្បួនគរុកោសល្យសម័យទំនើប ដែលជាសម័យជឿនលឿនដោ-យបញ្ញាស្មារតីនិងសីលធម៌មានមេត្តាករុណាជាដើមទៀតផង ។ សម័យកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) វិញ ជាសម័យខ្មៅងងឹតរបស់ខ្មែរ ។ កុមារខ្មែរទាំងអស់បានត្រូវខ្មែរក្រហមបញ្ជូនឲ្យធ្វើពលកម្ម ធ្វើជាយោធា ធ្វើជាកងឈ្លបនិងធ្វើពលកម្មការងារប្រចាំថ្ងៃដទៃទៀត ។ ខ្មែរក្រហមបានឲ្យកុមាររៀនអក្សរគ្រាន់តែចេះអាន ដើម្បីស្រណុកទន្ទេញមនោគមវិជ្ជាកុម្មុយនិស្ត ។ កុមារមានសិទ្ធិរស់រានមានជីវិត មានសិទ្ធិរៀនសូត្រ ប៉ុន្តែខ្មែរក្រហមបានប្រើកុមារឲ្យបំ-ពេញពលកម្មដូចមនុស្សចាស់ ផ្តល់ចំណីអាហារពុំគ្រប់គ្រាន់ ធ្វើឲ្យកុមារមានជម្ងឺ ដោយបាក់កម្លាំងនិងខ្វះជីវជាតិ ។ កុមារខ្លះបានត្រូវស្លាប់ និងកុមារខ្លះបានត្រូវខ្មែរក្រហមយកទៅសម្លាប់ចោល ដោយមានកំហុសបន្តិចបន្តួច ដែលខ្មែរក្រហមចោទថាខុសនឹងមាគ៌ាបក្ស ដោយគ្មានការជំនុំជំរះឲ្យបានត្រឹមត្រូវឡើយ។ គួរឲ្យរន្ធត់មួយទៀត គឺខ្មែរក្រហមសម្លាប់ទាំងគ្រួសារ រួមទាំងកុមារដែលជាកូនចៅ បើឪពុកម្តាយធ្វើជាអ្នករដ្ឋការ មានបណ្តាស័ក្តិធំ ឬធ្វើទាហានមានឋានៈខ្ពស់ ដោយពាក្យស្លោកគេថា «ជីកស្មៅ ជីកទាំងឫស» ។

នៅប្រទេសកម្ពុជា តាមពត៌មានថា មានកុមារខ្មែររាប់ពាន់នាក់ ភាគច្រើនកុមារីដែលមានអាយុក្រោម១៨ឆ្នាំ បានទៅបំរើគេតាមផ្ទះ ដោយឲ្យប្រាក់ខែបន្តិចបន្តួច ហើយមិនឲ្យរៀនសូត្រទេ ។ មានកុមារីខ្មែរខ្លះ បានត្រូវម្ចាស់ផ្ទះប្រើឲ្យធ្វើការស្ទើរគ្មានពេលសំរាក ហើយមានពេលខ្លះបានវាយធ្វើបាបផង ។ មានកុមារីខ្មែរតិចណាស់ ដែលម្ចាស់ផ្ទះ (ចៅហ្វាយនាយ) យកមកបំរើទុកដូចជាកូនហើយបញ្ជូនឲ្យទៅសាលារៀន ។ ការជួលកុមារឲ្យបំរើខ្លួនតាមផ្ទះ ជាការខុសច្បាប់ បើកុមារអាយុក្រោម១៨ឆ្នាំ ។ បើឲ្យកុមារធ្វើការច្រើនម៉ោងហួសកម្លាំង

ហើយវាយដំផង នេះជាការរំលោភសិទ្ធិកុមារ ។ រដ្ឋនឹងផ្តន្ទាទោសតាមច្បាប់ ។

ព្រះពុទ្ធសាសនាសំដែងថា ចៅហ្វាយនាយត្រូវទំនុកបំរុងអ្នកបំរើដោយធម៌ប្រាំយ៉ាង ៖ ចាត់ចែងការងារឲ្យធ្វើតាមសមគួរដល់កម្លាំង, ឲ្យភោជនាហារនិងរង្វាន់ (ឲ្យប្រាក់ខែសមរម្យ), ព្យាបាលក្នុងពេលមានជម្ងឺ, ចែកភោជនាហារដែលមានរសប្រណីត (ផ្តល់រង្វាន់ពិសេសលើកទឹកចិត្ត), បើកការសប្បាយក្នុងការគួរ (ឲ្យឈប់សំរាកធ្វើការក្នុងពេលមានបុណ្យទានរបស់ជាតិ) ។

ចាប់ពីទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារពីឆ្នាំនេះទៅ អ្នកដែលរំលោភលើសិទ្ធិកុមារខ្មែរ ត្រូវតែឈប់ប្រព្រឹត្ត ព្រោះអំពើនេះខុសនឹងច្បាប់អន្តរជាតិផង ខុសនឹងផ្លូវធម៌របស់ព្រះពុទ្ធសាសនាផង ។ ជាពិសេស ចំពោះអ្នកដែលយកយុវជននិងយុវនារីខ្មែរ ដែលមានអាយុ១៨ឆ្នាំ ឬលើសពី១៨ឆ្នាំ ឲ្យមកបំរើក្នុងផ្ទះរបស់ខ្លួន គួរមានធម៌មេត្តា ត្រូវចាត់ទុកជាកូនចៅរបស់ខ្លួន កុំយកមកបំរើដូចជាខ្ញុំងារថ្លៃ ។ យុវជនខ្មែរជាអនាគតរបស់ជាតិ នឹងបន្តវេនពីចាស់ ដូច្នេះគួររក្សាពួកគេឲ្យបានល្អ អ្នកនឹងមានបុណ្យកុសលច្រើនណាស់ ។៚

❄ ❄

❄